ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
# ឃុំទំនប់
# រយៈពេល ៣ ឆ្នាំ ( មីនា ២០១៨ - កុម្ភៈ ២០២១ )

| | |
|---|---|
| ឈ្មោះសហគមន៍នេសាទ | ៖ ឃុំទំនប់ |
| ភូមិ | ៖ ទំនប់ ប្រយុក ស្រឹង<br>ដូនប៉ែន រូង ប្រសាំ<br>និងត្រពាំងស្នោ |
| ឃុំ | ៖ ទំនប់ |
| ស្រុក | ៖ បាធាយ |
| ខេត្ត | ៖ កំពង់ចាម |

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងតំបន់នេសាទសហគមន៍
# ឃុំទំនប់
# រយៈពេល ៣ឆ្នាំ ( មីនា ២០១៨ - កុម្ភៈ ២០២១ )

| | | |
|---|---|---|
| ឈ្មោះសហគមន៍នេសាទ | ៖ | ឃុំទំនប់ |
| ភូមិ | ៖ | ទំនប់ ប្រយុក ស្រឹង ដូនប៉ែន រូង ប្រសាំ និងត្រពាំងស្មោ |
| ឃុំ | ៖ | ទំនប់ |
| ស្រុក | ៖ | បាធាយ |
| ខេត្ត | ៖ | កំពង់ចាម |

# មាតិកា
## ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍


**១- ស្ថានភាពទូទៅ**..............................១

**២- អំពីប្រជាសាស្ត្រនិងសេដ្ឋកិច្ចសង្គម**..............................១

ក- ប្រជាពលរដ្ឋ..............................១

ខ- មុខរបរ..............................២

**៣- កន្លែងនេសាទសហគមន៍ និងធនធានដែលមាននៅក្នុងកន្លែងនេសាទសហគមន៍**..............................២

ក- ទីតាំង..............................២

ខ- ដែននេសាទ..............................២

គ- តំបន់ដែលមានលទ្ធភាពបង្កើតកន្លែងអភិរក្ស..............................៣

ឃ- ធនធានជលផល..............................៣

**៤- ការធ្វើនេសាទ**..............................៣

ក- អ្នកនេសាទ..............................៣

ខ- ឧបករណ៍នេសាទ..............................៣

គ- ការប៉ាន់ប្រមាណផលចាប់ប្រចាំឆ្នាំ..............................៥

**៥- ផែនការគ្រប់គ្រងសហគមន៍នេសាទ**..............................៦

ក- ទស្សនវិស័យ..............................៦

ខ- គោលបំណង..............................៦

គ- ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍..............................៦

គ១- ផែនការប្រើប្រាស់ឧបករណ៍នេសាទ..............................៥

គ២- ផែនការកែលម្អកន្លែងនេសាទសហគមន៍..............................៧

គ៣- ផែនការកំណត់និងរៀបចំកន្លែងអភិរក្ស..............................៨

គ៤- ផែនការគ្រប់គ្រងព្រៃលិចទឹក..............................៨

គ៥- ផែនការទប់ស្កាត់បទល្មើសជលផល..............................៩

គ៦- ផែនការប្រជុំប្រចាំខែនិងទិញសម្ភារអនុវត្តន៍ការងាររបស់គណៈកម្មការសហគមន៍នេសាទ.....១០

គ៧- ផែនការផ្សព្វផ្សាយនិងបណ្តុះបណ្តាល..............................១០

គ៨- ផែនការបង្កើតមុខរបរសមាជិកក្នុងសហគមន៍នេសាទ..............................១២

គ៩- ផែនការបង្កើតកន្លែងទស្សនាកំសាន្តក្នុងសហគមន៍នេសាទ (អេកូទេសចរណ៍)..............................១៣

គ១០- ផែនការសាងសង់ស្នាក់ការសហគមន៍នេសាទ..............................១៤

គ១១- ផែនការបង្កើតក្រុមឥណទានដើម្បីបង្កើនមុខរបរ..............................១៤

គ១២- ផែនការអភិវឌ្ឍន៍វារីវប្បកម្មក្នុងសហគមន៍នេសាទ..............................១៥

គ១៣- ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍..............................១៥

ឃ. ផែនការយុទ្ធសាស្ត្រ..............................១៦

- តារាងកម្មវិធីការងារ..............................១៧

# ផែនការគ្រប់គ្រង
# កន្លែងនេសាទសហគមន៍

## ១ ស្ថានភាពទូទៅ

សហគមន៍នេសាទឃុំទំនប់ បានធ្វើមហាសន្និបាតកំណើតដំបូងរបស់សហគមន៍នេសាទនៅឆ្នាំ២០០៩ និងបានធ្វើមហាសន្និបាតលើកទី២ នៅថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៦ និងបានធ្វើកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៦ ។

សហគមន៍នេសាទឃុំទំនប់ មានទីតាំងស្ថិតនៅក្នុងភូមិទំនប់ ប្រយុក ដូនប៉ែន រូង ប្រសាំ និងភូមិស្រឹង ឃុំទំនប់ ស្រុកបាធាយ ខេត្តកំពង់ចាម ។ ដែលមានសមាជិកសហគមន៍នេសាទសរុបចំនួន១៤០នាក់ ក្នុងនោះ ប្រុស៩៣នាក់ ស្រី៤៧នាក់ ក្នុងនោះចំនួនគ្រួសារសរុបមានចំនួន១៤០ គ្រួសារ។ មានគណៈកម្មការចំនួន០៩នាក់ ស្រីគ្មាន និងមានក្រុមល្បាតចំនួន១២នាក់ ។

កន្លងមកសហគមន៍នេសាទនេះ បានដំណើរការសកម្មភាពសំខាន់ៗ របស់ខ្លួនរួមមាន ៖

- បោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទ
- រៀបចំបញ្ជីឈ្មោះសមាជិកនិងគណៈកម្មការសហគមន៍នេសាទ
- រៀបចំរចនាសម្ព័ន្ធគណៈកម្មការសហគមន៍នេសាទ
- រៀបចំលក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ
- រៀបចំកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍
- កំណត់ព្រំប្រទល់កន្លែងនេសាទសហគមន៍និងធ្វើផែនទី
- ស្នើសុំចុះបញ្ជីនៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ទប់ស្កាត់បទល្មើសនេសាទក្នុងកន្លែងនេសាទសហគមន៍
- ការពារព្រៃលិចទឹក
- បង្កើតកន្លែងអភិរក្សត្រីមេពូជ
- ការពារកន្លែងអភិរក្សត្រីមេពូជ
- ចូលរួមសិក្ខាសាលាស្តីពីវឌ្ឍនភាពនៃដំណើរការអនុវត្តន៍ការគ្រប់គ្រងសហគមន៍នេសាទ
- ចូលរួមប្រជុំជាមួយភូមិ ឃុំ ស្រុក
- ប្រមូលព័ត៌មានទូទៅសំរាប់ធ្វើផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍។

## ២ អំពីប្រជាសាស្ត្រនិងសេដ្ឋកិច្ចសង្គម

### ក. ប្រជាសាស្ត្រ

ចំនួនប្រជាពលរដ្ឋសរុបក្នុងតំបន់មាន៥.៩៥៤នាក់ ស្រី៣.២៥៣នាក់ ត្រូវជា ១.៣៣១ គ្រួសារ។ ប្រជាពលរដ្ឋក្នុងតំបន់ជាអ្នកកាន់សាសនាព្រះពុទ្ធ១០០%។

ក្នុងចំណោមសមាជិកគ្រួសារនៃសមាជិកសហគមន៍នេសាទទាំងអស់ អ្នកមិនចេះអក្សរចំនួន១២នាក់ ស្រី៧នាក់ កម្រិតថ្នាក់បឋមសិក្សាចំនួន៦១នាក់ ស្រី២៤នាក់ កម្រិតអនុវិទ្យាល័យមានចំនួន៤៩នាក់ ស្រី១២នាក់ ថ្នាក់វិទ្យាល័យ១៨នាក់ ស្រី៤នាក់ និងកម្រិតថ្នាក់ឧត្តមសិក្សាគ្មាន ។

- ចំនួនស្ត្រីមេម៉ាយក្នុងសហគមន៍នេសាទមាន៧នាក់

- ចំនួនជនពិការក្នុងសហគមន៍នេសាទមាន១នាក់ ស្រីគ្មាន
- ចំនួនចាស់ជរាក្នុងសហគមន៍នេសាទមាន៧នាក់ ស្រី៤នាក់
- ចំនួនកុមារកំព្រាក្នុងសហគមន៍នេសាទគ្មាន
- ចំនួនអ្នកជម្ងឺរ៉ាំរ៉ៃក្នុងសហគមន៍នេសាទមាន០១នាក់ ស្រី០១នាក់ ។

**ខ. មុខរបរ**

មុខរបរសំខាន់ៗរបស់សមាជិកក្នុងសហគមន៍នេសាទនេះរួមមាន៖

- ធ្វើនេសាទចំនួន៧២នាក់ ចំនួន៧២គ្រួសារ
- ធ្វើស្រែចំនួន១១២គ្រួសារ ទំហំ០,៥-៤ហិកតា
- ធ្វើចំការចំនួន៥គ្រួសារ
- ធ្វើវារីវប្បកម្មចំនួន១០គ្រួសារ ស្រះចំនួន១០ស្រះ ទំហំ១៥មx២០ម x៣ម
- ជាងផ្ទះចំនួន១២គ្រួសារ
- ជាងឡាន ម៉ូតូ ៦គ្រួសារ
- លក់ដូរចំនួន១៤គ្រួសារ
- កម្មករ៤២គ្រួសារ
- មន្ត្រីរាជការ១៥គ្រួសារ ។
- ប្រាក់ចំណូលជាមធ្យមក្នុងគ្រួសារប្រចាំឆ្នាំមានចំនួន ១៥.៥៤៩.០០០ រៀល ។

## ៣ កន្លែងនេសាទសហគមន៍និងធនធានដែលមាននៅក្នុងកន្លែងនេសាទសហគមន៍

**ក. ទីតាំង**

កន្លែងនេសាទសហគមន៍ឃុំទំនប់ ជាដែននេសាទទឹកសាប គ្របដណ្តប់ទៅដោយធនធានធម្មជាតិមួយចំនួនដូចជាទំនប់ ត្រពាំង អាងទឹក អូរ ប្រឡាយ វាលស្មៅ ព្រៃលិចទឹក សត្វស្លាប ត្រីមេពូជ និងទេសភាពស្ថិតក្នុងខេត្តកំពង់ចាម មានទំហំ ៣៦,២ ហិកតា និងមានកន្លែងអភិរក្សត្រីមេពូជចំនួន២កន្លែងសរុបទំហំ ១,៣១២ ហិកតាដោយមានកំណត់និយាមកាដូចមានចែងនៅក្នុងកិច្ចព្រមព្រៀង ។

មានព្រំប្រទល់ ៖

ខាងជើងទល់នឹងផ្លូវកៅស៊ូ ភូមិប្រយុក ឃុំទំនប់ ស្រុកបាធាយ

- ខាងត្បូងទល់នឹងព្រំប្រទល់ឃុំជើងព្រៃ ស្រុកបាធាយ និងឃុំស្តើងជ័យ ស្រុកជើងព្រៃ
- ខាងកើតទល់នឹងឃុំទំនប់ខាងកើតឈៀងខាងត្បូង
- ខាងលិចទល់នឹងភូមិទំនប់ ឃុំទំនប់ ស្រុកបាយធាយ ។

**ខ. ដែននេសាទ**

កន្លែងនេសាទសហគមន៍នេសាទឃុំទំនប់ មានបឹងចំនួន៤បឹង ព្រែកចំនួន១ព្រែក និងដីទំនាបលិចទឹកគឺ៖

- ត្រពាំងទំនប់ ទំហំ ៨,២២ ហិកតា នេសាទពេញមួយឆ្នាំ
- ត្រពាំងស្មោ (ទឹកបាក់) ទំហំ ៩ ហិកតា នេសាទពេញមួយឆ្នាំ ។
- ដីទំនាបលិចទឹកមានទំហំសរុប ១៨,៩៨ ហិកតា។

គ. តំបន់ដែលមានលទ្ធភាពបង្កើតកន្លែងអភិរក្ស

- ត្រពាំងទំនប់ ទំហំ ០,៦៩៤ ហិកតា នេសាទពេញមួយឆ្នាំ
- ត្រពាំងស្មោ ចំណុចទឹកបាក់ ទំហំ ០,៦១៨ ហិកតា នេសាទពេញមួយឆ្នាំ ។

ឃ. ធនធានជលផល

-ប្រភេទត្រី ៖ ត្រីរ៉ស់ ត្រីដៀប ត្រីរៀល ត្រីក្រាញ់ ត្រីចង្វារ ត្រីឆ្តោង ត្រីឆ្លូញ ត្រីកន្ធ្រប់ ត្រីខ្ជាន់ ត្រីអណ្តែង ត្រីដំរី ត្រីតាអោន ត្រីក្រម៉ម ត្រីខ្ទឹង ត្រីកញ្ជនជ័យ ត្រីច្រកែង ត្រីកាហែ ត្រីស្រកាក្តាម ត្រីព្រលូង ត្រីក្រពាត់ ត្រីក្រុះ ត្រីកញ្ចាញ់ច្រាស់ ត្រីកំភ្លាញ ត្រីកញ្ចុះ ត្រីក្រឹម ត្រីទីឡាព្យ៉ា ត្រីកំពត កំពឹស ។ល។

-ប្រភេទវារីសត្វ ៖ អណ្តើក ពស់ ខ្យង ក្តាម អន្ទង់ ខ្ចៅ កង្កែប ឈ្លើង អន្ទង់។ល។

-ប្រភេទរុក្ខជាតិព្រៃលិចទឹកនិងវារីរុក្ខជាតិ ៖ ដើមថ្លើមអណ្តើក អូយយ៉ាស់(បន្លាយយួន) បន្លាស្អិត រាំង ប្របួយមេ អញ្ចាញ ត្រស់ ស្លាបទា ក្រចៅ វ សារាយ កំប្លោក ចកតូច ចកធំ ចកបាយទា កំពីងពួយ ត្រកួន ព្រលិត រំចង់ ស្មៅអន្ទក់ទឹក ស្មៅអំពៅខៀប ចំប្លង កក់ជ្រុង កញ្ឆែត ស្មៅថ្នក់ទឹក។ល។

## ៤. ការធ្វើនេសាទ

ក. អ្នកនេសាទ ៖

- អ្នកនេសាទជាសមាជិកសហគមន៍នេសាទមានចំនួន៧២នាក់ ស្រី២៨នាក់
- ប៉ាន់ស្មានអ្នកនេសាទមិនមែនជាសមាជិកសហគមន៍នេសាទនៅក្នុងសហគមន៍ មានចំនួន៥៣នាក់ ស្រី១៥នាក់
- ប៉ាន់ស្មានអ្នកនេសាទមិនមែនជាសមាជិកដែលមកពីក្រៅសហគមន៍មានចំនួន១៧នាក់ ស្រី៦នាក់។

ខ. ឧបករណ៍នេសាទ ៖

- ឧបករណ៍នេសាទនិងទូកកាណូតរបស់សមាជិកសហគមន៍នេសាទ ៖

| ប្រភេទ ឧបករណ៍ | ឯកតា | ចំនួន គ្រួសារ | ចំនួនឧបករណ៍ នេសាទ | ទំហំ/ប្រវែង | រដូវប្រើប្រាស់ឧបករណ៍ (ខែ....ដល់ខែ....) |
|---|---|---|---|---|---|
| សន្ទូចស្ទូច | ផ្លែ | ១២ | ២ផ្លែ/គ្រួសារ | ២៤ផ្លែ | ពេញរដូវនេសាទ |
| សន្ទូចរនង | ផ្លែ | ៧ | ១០០-២០០ផ្លែ/គ្រួសារ | ១.០៥០ផ្លែ | ខែកក្កដា ដល់ ខែធ្នូ |
| សន្ទូចបង្កៃ | ផ្លែ | ៦០ | ២០-៥០ផ្លែ/គ្រួសារ | ២.១០០ផ្លែ | ខែកក្កដា ដល់ ខែធ្នូ |
| ឈ្នាងជញ្ជាត់ | គ្រឿង | ១២ | ១គ្រឿង/គ្រួសារ | ១២គ្រឿង | ខែកក្កដា ដល់ ខែកុម្ភៈ |
| អង្រុត | គ្រឿង | ៤១ | ១គ្រឿង/គ្រួសារ | ៤១គ្រឿង | ខែធ្នូ ដល់ ខែមេសា |
| ទ្រូ | គ្រឿង | ២៤ | ២គ្រឿង/គ្រួសារ | ៤៨គ្រឿង | ខែកក្កដា ដល់ ខែមករា |
| លបត្រី | គ្រឿង | ៥ | ២គ្រឿង/គ្រួសារ | ១០គ្រឿង | ខែមិថុនា ដល់ ខែកុម្ភៈ |
| លបកង្កែប | គ្រឿង | ២៤ | ២០-៤០គ្រឿង/គ្រួសារ | ៧២០គ្រឿង | ខែមិថុនា ដល់ ខែកុម្ភៈ |
| មង | ម៉ែត្រ | ១៧ | ១០០-៣០០ម/គ្រួសារ | ៣.៤០០ម៉ែត្រ | ពេញរដូវនេសាទ |
| សំណាញ់ | វង់ | ៣០ | ១វង់/គ្រួសារ | ៣០វង់ | ពេញរដូវនេសាទ |

| | | | | | |
|---|---|---|---|---|---|
| ឈិបរុញដៃ | គ្រឿង | ៥ | ១គ្រឿង/គ្រួសារ | ៥គ្រឿង | ខែកក្កដា ដល់ ខែធ្នូ |
| ថ្នងអូសដៃ | គ្រឿង | ៧ | ១គ្រឿង/គ្រួសារ | ៧គ្រឿង | ខែកក្កដា ដល់ ខែធ្នូ |
| អួនអូសដៃ | វង់ | ១ | ៥០-១០០ម/វង់/គ្រួសារ | ៧៥ម៉ែត្រ | ខែធ្នូ ដល់ ខែមេសា |
| អួនប្រយ៉ុង | វង់ | ១ | ៥០-១០០ម/វង់/គ្រួសារ | ៧៥ម៉ែត្រ | ខែធ្នូ ដល់ ខែមេសា |
| អូសគន | វង់ | ២ | ៥០-១០០ម/វង់/គ្រួសារ | ១៥០ម៉ែត្រ | ខែធ្នូ ដល់ ខែមេសា |
| លាន់ | គ្រឿង | ១២ | ២០គ្រឿង/គ្រួសារ | ២៤០គ្រឿង | ខែកក្កដា ដល់ ខែធ្នូ |
| តុមអន្ទង់ | គ្រឿង | ១០ | ២០គ្រឿង/គ្រួសារ | ២០០គ្រឿង | ខែកក្កដា ដល់ ខែធ្នូ |
| កង្វាត្រីឆ្លូញ | គ្រឿង | ៦ | ១គ្រឿង/គ្រួសារ | ៦គ្រឿង | ខែមីនា ដល់ ខែឧសភា |
| សាង | គ្រឿង | ២៤ | ១គ្រឿង/គ្រួសារ | ២៤គ្រឿង | ខែកក្កដា ដល់ ខែធ្នូ |

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កំលាំងសេះ |
|---|---|---|---|
| ទូកមានម៉ាស៊ីន | គ្មាន | - | - |
| ទូកអុំ ឬចែវ | ២ គ្រឿង | ៥០-១០០ គីឡូក្រាម | - |

ឧបករណ៍នេសាទនិងទូកកាណូតរបស់អ្នកនៅក្នុងតំបន់ប៉ុន្តែមិនមែនជាសមាជិកសហគមន៍នេសាទ ៖

| ប្រភេទ ឧបករណ៍ | ឯកតា | ចំនួន គ្រួសារ | ចំនួនឧបករណ៍ នេសាទ | ទំហំ/ប្រវែង | រដូវប្រើប្រាស់ឧបករណ៍ (ខែ....ដល់ខែ....) |
|---|---|---|---|---|---|
| សន្ទូចស្ទូច | ផ្លែ | ១៨ | ២ផ្លែ/គ្រួសារ | ៣៦ផ្លែ | ពេញរដូវនេសាទ |
| សន្ទូចរនង | ផ្លែ | ១១ | ១០០-២០០ផ្លែ/គ្រួសារ | ១.៦៥០ផ្លែ | ខែកក្កដា ដល់ ខែធ្នូ |
| សន្ទូចបង្កៃ | ផ្លែ | ៩០ | ២០-៥០ផ្លែ/គ្រួសារ | ៣.១៥០ផ្លែ | ខែកក្កដា ដល់ ខែធ្នូ |
| ឈ្នាងជញ្ជាត់ | គ្រឿង | ១៨ | ១គ្រឿង/គ្រួសារ | ១៨គ្រឿង | ខែកក្កដា ដល់ ខែកុម្ភៈ |
| អង្រុត | គ្រឿង | ៦១ | ១គ្រឿង/គ្រួសារ | ៦១គ្រឿង | ខែធ្នូ ដល់ ខែមេសា |
| ទ្រូ | គ្រឿង | ៣៦ | ២គ្រឿង/គ្រួសារ | ៧២គ្រឿង | ខែកក្កដា ដល់ ខែមករា |
| លបត្រី | គ្រឿង | ៧ | ២គ្រឿង/គ្រួសារ | ១៤គ្រឿង | ខែមិថុនា ដល់ ខែកុម្ភៈ |
| លបកង្កែប | គ្រឿង | ៣៦ | ២០-៤០គ្រឿង/គ្រួសារ | ១.០៨០គ្រឿង | ខែមិថុនា ដល់ ខែកុម្ភៈ |
| មង | ម៉ែត្រ | ៩ | ១០០-៣០០ម/គ្រួសារ | ១.៨០០ម៉ែត្រ | ពេញរដូវនេសាទ |
| សំណាញ់ | វង់ | ៤៥ | ១វង់/គ្រួសារ | ៤៥វង់ | ពេញរដូវនេសាទ |
| ឈិបរុញដៃ | គ្រឿង | ៧ | ១គ្រឿង/គ្រួសារ | ៧គ្រឿង | ខែកក្កដា ដល់ ខែធ្នូ |
| ថ្នងអូសដៃ | គ្រឿង | ១១ | ១គ្រឿង/គ្រួសារ | ១១គ្រឿង | ខែកក្កដា ដល់ ខែធ្នូ |
| អួនអូសដៃ | វង់ | ២ | ៥០-១០០ម/វង់/គ្រួសារ | ១៥០ម៉ែត្រ | ខែធ្នូ ដល់ ខែមេសា |
| អួនប្រយ៉ុង | វង់ | ២ | ៥០-១០០ម/វង់/គ្រួសារ | ១៥០ម៉ែត្រ | ខែធ្នូ ដល់ ខែមេសា |
| អូសគន | វង់ | ១ | ៥០-១០០ម/វង់/គ្រួសារ | ៧៥ម៉ែត្រ | ខែធ្នូ ដល់ ខែមេសា |
| លាន់ | គ្រឿង | ១៨ | ២០គ្រឿង/គ្រួសារ | ៣៦០គ្រឿង | ខែកក្កដា ដល់ ខែធ្នូ |

| | | | | | |
|---|---|---|---|---|---|
| តុមអន្ទង់ | គ្រឿង | ១៥ | ២០គ្រឿង/គ្រួសារ | ៣០០គ្រឿង | ខែកក្កដា ដល់ ខែធ្នូ |
| កង្វាត្រីឆ្លូញ | គ្រឿង | ៩ | ១គ្រឿង/គ្រួសារ | ៩គ្រឿង | ខែមីនា ដល់ ខែឧសភា |
| សាង | គ្រឿង | ៣៦ | ១គ្រឿង/គ្រួសារ | ៣៦គ្រឿង | ខែកក្កដា ដល់ ខែធ្នូ |

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កំលាំងសេះ |
|---|---|---|---|
| ទូកមានម៉ាស៊ីន | គ្មាន | - | - |
| ទូកអុំ ឬចែវ | ២ គ្រឿង | ៥០-១០០ គីឡូក្រាម | - |

- ឧបករណ៍នេសាទនិងទូកកាណូតរបស់អ្នកមិនមែនជាសមាជិកសហគមន៍ដែលមកពីខាងក្រៅសហគមន៍៖

| ប្រភេទឧបករណ៍ | ឯកតា | ចំនួនគ្រួសារ | ចំនួនឧបករណ៍នេសាទ | ទំហំ/ប្រវែង | រដូវប្រើប្រាស់ឧបករណ៍ (ខែ....ដល់ខែ....) |
|---|---|---|---|---|---|
| មងពាក់ | ម៉ែត្រ | ៤ | ១០០- ៣០០ម/គ្រួសារ | ៨០០ ម៉ែត្រ | ពេញរដូវនេសាទ |
| ឈិបរុញដៃ | គ្រឿង | ៣ | ១គ្រឿង/គ្រួសារ | ៣គ្រឿង | ខែកក្កដា ដល់ ខែធ្នូ |
| សន្ទូចរនង | ផ្លែ | ៤ | ១០០-២០០ផ្លែ/គ្រួសារ | ៦០០ផ្លែ | ខែកក្កដា ដល់ ខែធ្នូ |
| ថ្នងអូសដៃ | គ្រឿង | ៦ | ១គ្រឿង/គ្រួសារ | ៦គ្រឿង | ខែកក្កដា ដល់ ខែធ្នូ |
| អូសគន | វង់ | ២ | ៥០-១០០ម/វង់/គ្រួសារ | ១៥០ម៉ែត្រ | ខែធ្នូ ដល់ ខែមេសា |
| លាន់ | គ្រឿង | ២ | ៣០គ្រឿង/គ្រួសារ | ៦០គ្រឿង | ខែកក្កដា ដល់ ខែធ្នូ |
| តុមអន្ទង់ | គ្រឿង | ៥ | ២០គ្រឿង/គ្រួសារ | ១០០គ្រឿង | ខែកក្កដា ដល់ ខែធ្នូ |
| កង្វាត្រីឆ្លូញ | គ្រឿង | ២ | ១គ្រឿង/គ្រួសារ | ២គ្រឿង | ខែមីនា ដល់ ខែឧសភា |
| សាង | គ្រឿង | ៣ | ១គ្រឿង/គ្រួសារ | ៣គ្រឿង | ខែកក្កដា ដល់ ខែធ្នូ |

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កំលាំងសេះ |
|---|---|---|---|
| ទូកមានម៉ាស៊ីន | គ្មាន | - | - |
| ទូកអុំ ឬចែវ | គ្មាន | - | - |

គ. ការប៉ាន់ប្រមាណផលចាប់បានប្រចាំឆ្នាំ

| ប្រភេទផលនេសាទ | បរិមាណផលនេសាទចាប់បានគិតជាមធ្យមប្រចាំគ្រួសារ (គ្រួសារអ្នកនេសាទ) | | |
|---|---|---|---|
| | រដូវប្រាំង | រដូវវស្សា | សរុបប្រចាំឆ្នាំ |
| ត្រីចម្រុះ | ១៩៧ គីឡូក្រាម | ២៦៨ គីឡូក្រាម | ៤៦៥ គីឡូក្រាម |
| ខ្យង/ខ្ចៅ | ៨៦ គីឡូក្រាម | ១៨៤ គីឡូក្រាម | ២៧០ គីឡូក្រាម |

## ៥-ផែនការគ្រប់គ្រងសហគមន៍នេសាទ

### ក. ទស្សនវិស័យ ៖

សហគមន៍នេសាទឃុំទំនប់ មានទស្សនវិស័យចូលរួមគ្រប់គ្រងធនធានជលផលប្រកបដោយសមធម៌ និង ចីរភាព ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ។

### ខ. គោលបំណង ៖

- ចូលរួមគ្រប់គ្រងដែននេសាទទឹកសាបដែលបានលុបពីឡូត៍នេសាទ កន្លែងនេសាទគ្រួសារដែលរក្សាទុកសម្រាប់ប្រជាពលរដ្ឋធ្វើនេសាទជាប្រពៃណី ឬ សហគមន៍ធ្វើនេសាទ កន្លែងនេសាទបំរុង ទំនាបលិចទឹកក្នុងរដូវដំឡើង នាទីព្រៃលិចទឹក
- ចូលរួមគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តភាព និងធានាការបែងចែកផលប្រយោជន៍ ធនធានជលផលជូនប្រជាពលរដ្ឋខ្មែរប្រកបដោយសមធម៌
- ដើម្បីធ្វើឱ្យប្រសើរឡើងនូវជីវភាពសមាជិកសហគមន៍ តាមរយៈការអភិវឌ្ឍចម្រុះដោយមានការចូលរួម
- ដើម្បីឱ្យប្រជាពលរដ្ឋខ្មែរបានយល់ច្បាស់ហើយឈានទៅចាត់ទុកថាខ្លួនជាម្ចាស់លើធនធានធម្មជាតិ ។

### គ. ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

#### គ.១ ផែនការប្រើប្រាស់ឧបករណ៍នេសាទ

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ គឺរៀបចំឡើងដោយគិតគូរពីប្រភេទដែននេសាទ ប្រភេទ ទំហំ ប្រវែង ចំនួនឧបករណ៍នេសាទ ចំនួនអ្នកនេសាទ និងរដូវនេសាទ ។

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ត្រូវបានរៀបចំឡើងដូចខាងក្រោម ៖

| ឈ្មោះ/ទីតាំង កន្លែងនេសាទ | ពេលវេលា ធ្វើនេសាទ | ឧបករណ៍នេសាទអនុញ្ញាតឱ្យប្រើ | | | ផ្សេងៗ |
|---|---|---|---|---|---|
| | | ប្រភេទ | ទំហំ/ប្រវែង | ចំនួន (ក្នុងពេលតែមួយ) | |
| -ត្រពាំងទំនប់<br>-ត្រពាំងស្មោ<br>-ទំនាបលិចទឹក | ពេញរដូវនេសាទ | សន្ទូចស្ទូច | ១ថ្លៃ/គ្រួសារ | មិនកំណត់ | សមាជិកនិងអ្នកមិនមែនសមាជិកសហគមន៍នេសាទ |
| | ខែកក្កដា ដល់ ខែធ្នូ | សន្ទូចរនង | ១៥០ថ្លៃ/គ្រួសារ | ១៥គ្រួសារ | |
| | ខែកក្កដា ដល់ ខែធ្នូ | សន្ទូចបង្កៃ | ៣៥ថ្លៃ/គ្រួសារ | មិនកំណត់ | |
| | ខែកក្កដា ដល់ ខែកុម្ភៈ | ឈ្នាងជញ្ជាត់ | ១គ្រឿង/គ្រួសារ | មិនកំណត់ | |
| | ខែធ្នូ ដល់ ខែមេសា | អង្រុត | ១គ្រឿង/គ្រួសារ | មិនកំណត់ | |
| | ខែកក្កដាដល់ខែមករា | ទ្រូ | ២គ្រឿង/គ្រួសារ | មិនកំណត់ | |
| | ខែមិថុនា ដល់ ខែកុម្ភៈ | លបត្រី | ២គ្រឿង/គ្រួសារ | ៤គ្រួសារ | |
| | ខែមិថុនា ដល់ ខែកុម្ភៈ | លបកង្កែប | ៣០គ្រឿង/គ្រួសារ | ៤គ្រួសារ | |
| | ខែមិថុនាដល់ខែតុលា | មងពាក់ | ១០០ម/គ្រួសារ | ១៥គ្រួសារ | |
| | ខែវិច្ឆិកាដល់ខែឧសភា | | ២០០ម/គ្រួសារ | ១៥គ្រួសារ | |
| | ពេញមួយឆ្នាំ | សំណាញ់ | ១វង់/គ្រួសារ | មិនកំណត់ | |

| | | | | | |
|---|---|---|---|---|---|
| | ខែកក្កដា ដល់ ខែធ្នូ | ឈិបរុញដៃ | ១គ្រឿង/គ្រួសារ | ២០គ្រួសារ | |
| | ខែកក្កដា ដល់ ខែធ្នូ | ថ្នងអូសដៃ | ១គ្រឿង/គ្រួសារ | មិនកំណត់ | |
| | ខែធ្នូ ដល់ ខែមេសា | អួនអូសដៃ | ៣០ម/វង់/គ្រួសារ | ២គ្រួសារ | |
| | ខែធ្នូ ដល់ ខែមេសា | អួនប្រយុង | ៣០ម/វង់/គ្រួសារ | ២គ្រួសារ | |
| | ខែធ្នូ ដល់ ខែមេសា | អូសគន | ៣០ម/វង់/គ្រួសារ | ១០គ្រួសារ | |
| | ខែកក្កដា ដល់ ខែធ្នូ | លាន់ | ២០គ្រឿង/គ្រួសារ | ១០គ្រួសារ | |
| | ខែកក្កដា ដល់ ខែធ្នូ | តុមអន្ទង់ | ២០គ្រឿង/គ្រួសារ | ១០គ្រួសារ | |
| | ខែមីនាដល់ខែឧសភា | កង្វាត្រីឆ្លូញ | ១គ្រឿង/គ្រួសារ | មិនកំណត់ | |
| | ខែកក្កដា ដល់ ខែធ្នូ | សាង | ១គ្រឿង/គ្រួសារ | មិនកំណត់ | |

### គ.២ ផែនការកែលម្អកន្លែងនេសាទសហគមន៍

ផែនការកែលម្អដែននេសាទ ត្រូវបានរៀបចំឡើងដូចមាននៅក្នុងតារាងខាងក្រោម ៖

| ឈ្មោះដែននេសាទ | ទំហំ(ហ.ត) ត្រូវអភិរក្ស | ប្រភេទនៃការអភិរក្ស | សកម្មភាព | ប៉ាន់ប្រមាណតម្លៃ(ដុល្លា) | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|---|
| កន្លែងនេសាទសហគមន៍ឃុំទំនប់ | ៣៦,២ | ៣៦,២ ហិកតា | ចុះកំណត់ចំណុចទីតាំងជាក់ស្តែងលើផែនដីតាមនិយាមកាលើផែនទី ឬបង្គោលជាក់ស្តែង | ១០០ | ២០១៨ | ២០១៩ |
| | | | ប្រជុំផ្សព្វផ្សាយដល់អ្នកពាក់ព័ន្ធ | ២០០ | ២០១៨ | ២០១៩ |
| | | | សាងសង់បង្គោលធ្វើពីស៊ីម៉ង់ដោយសរសេរអក្សរលើបង្គោលចំនួន២៤បង្គោល | ៤.០៨០ | ២០១៨ | ២០១៩ |
| ត្រពាំងទំនប់ | ១៧,៤ | ៣០មx១០០មx៣ម = ៩.០០០ម³ | ប្រជុំផ្សព្វផ្សាយដល់អ្នកពាក់ព័ន្ធ | ៣០០ | ២០១៨ | ២០១៩ |
| | | | សិក្សានិងកំណត់ទីតាំង | ២០០ | ២០១៨ | ២០១៩ |
| | | | ប្រើគ្រឿងចក្រស្តារឡើងវិញចំណុចកន្លែងអភិរក្សត្រីមេពូជ អាចម៍ដីរៀបចំជុំវិញត្រពាំងទំនប់ | ៩.០០០ | ២០១៨ | ២០១៩ |
| ត្រពាំងស្មោ | ១៨,៨ | ៤០មx១០០មx ៣ម = ១២.០០០ម³ | ប្រជុំផ្សព្វផ្សាយ | ២០០ | ២០២០ | ២០២១ |
| | | | សិក្សានិងកំណត់ទីតាំង | ២០០ | ២០២០ | ២០២១ |
| | | | ប្រើគ្រឿងចក្រស្តារឡើងវិញចំណុចកន្លែងអភិរក្សត្រីមេពូជ | ១២.០០០ | ២០២០ | ២០២១ |
| | | ៧មx(២ម/៤ម)x១ម | សាងសង់ទំនប់បង្ហៀរ | ៣.៦០០ | ២០២០ | ២០២១ |

### គ.៣ ផែនការកំណត់និងរៀបចំកន្លែងអភិរក្ស

ផែនការកំណត់និងរៀបចំកន្លែងអភិរក្សនឹង ត្រូវរៀបចំឡើងដូចមាននៅក្នុងតារាងខាងក្រោម៖

| ឈ្មោះដែននេសាទ | ទំហំ(ហ.ត) ត្រូវអភិរក្ស | ប្រភេទនៃការអភិរក្ស | សកម្មភាព | ប៉ាន់ប្រមាណតម្លៃ(ដុល្លា) | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្ដើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|---|
| ត្រពាំងទំនប់ | ០,៦៩៤ | ត្រីមេពូជ | ផ្សព្វផ្សាយពីកន្លែងអភិរក្ស និងការហាមឃាត់ដល់ប្រជាពលរដ្ឋឱ្យបានទូលំទូលាយ | ២០០ | ២០១៨ | ២០១៩ |
| | | | បោះបង្គោលព្រំស៊ីម៉ង់តំបន់អភិរក្ស ចំនួន៤បង្គោល | ២.០០០ | ២០១៨ | ២០១៩ |
| | | | ដាក់ស្លាកសញ្ញាចំនួន២ស្លាក | ១៥០ | ២០១៨ | ២០១៩ |
| ត្រពាំងស្មោ | ០,៦១៨ | ត្រីមេពូជ | ផ្សព្វផ្សាយពីកន្លែងអភិរក្ស និងការហាមឃាត់ដល់ប្រជាពលរដ្ឋឱ្យបានទូលំទូលាយ | ២០០ | ២០១៩ | ២០២០ |
| | | | បោះបង្គោលព្រំស៊ីម៉ង់តំបន់អភិរក្ស ចំនួន៤បង្គោល | ២.០០០ | ២០១៩ | ២០២០ |
| | | | ដាក់ស្លាកសញ្ញាចំនួន២ស្លាក | ១៥០ | ២០១៩ | ២០២០ |

### គ.៤ ផែនការគ្រប់គ្រងព្រៃលិចទឹក

ផែនការគ្រប់គ្រងព្រៃលិចទឹកត្រូវបានរៀបចំឡើងវិញ ដោយដកហូតមកវិញដីព្រៃលិចទឹក ដូចមាននៅក្នុងតារាងខាងក្រោម៖

| ឈ្មោះដែននេសាទ | ទំហំ (ហ.ត) | ប្រភេទព្រៃឈើការពារ | សកម្មភាព | | ប៉ាន់ប្រមាណតម្លៃ(ដុល្លា) | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្ដើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|---|---|
| ត្រពាំងទំនប់ | ១៧,៤ហិកតា | ព្រៃលិចទឹក | ផ្សព្វផ្សាយពីកន្លែងព្រៃលិចទឹកឱ្យបានទូលំទូលាយ | ចែកឯកសារ | ២០០ | ២០១៨ | ២០១៩ |
| | | | | ប្រជុំ | ៣០០ | | |
| | | | បោះបង្គោលព្រំព្រៃលិចទឹកចំនួន ៧ បង្គោល និងសរសេរស្លាកសញ្ញា | | ២៨០ | ២០១៨ | ២០១៩ |
| ត្រពាំងស្មោ | ១៨,៨ហិកតា | ព្រៃលិចទឹក | ផ្សព្វផ្សាយពីកន្លែងព្រៃលិចទឹកឱ្យបានទូលំទូលាយ | ចែកឯកសារ | ២០០ | ២០១៩ | ២០២០ |
| | | | | ប្រជុំ | ៣០០ | ២០១៩ | ២០២០ |
| | | | បោះបង្គោលព្រំព្រៃលិចទឹកចំនួន១៥បង្គោល និងសរសេរស្លាកសញ្ញា | | ៦០០ | ២០១៩ | ២០២០ |

គ៥-ផែនការទប់ស្កាត់បទល្មើសជលផល

ផែនការចុះទប់ស្កាត់បទល្មើសជលផល ត្រូវបានរៀបចំដូចខាងក្រោម៖

| សកម្មភាព | លទ្ធផលរំពឹងទុក | ប៉ាន់ប្រមាណតម្លៃ(ដុល្លា) | អ្នកចូលរួម | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| ផ្សព្វផ្សាយ<br>-ផ្សព្វផ្សាយតាមមេក្រូ ៣ថ្ងៃ/ឆ្នាំ<br>-ផ្សព្វផ្សាយបិទឯកសារ១ដង/ឆ្នាំ<br>-ប្រជុំផ្សព្វផ្សាយ១ដង/ឆ្នាំ<br>(មិថុនា/រៀងរាល់ឆ្នាំ) | -មានការយល់ដឹងពីការប្រើប្រាស់ឧបករណ៍នេសាទនិងសារៈសំខាន់នៃធនធានជលផល<br>-មានការយល់ដឹងពីការគ្រប់គ្រងសហគមន៍នេសាទ<br>-ការប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់ថយចុះ | ៤៥០ | -គណៈកម្មការ សមាជិកស.ន<br>-អាជ្ញាធរមូលដ្ឋាន<br>-ជំនាញ<br>-អង្គការដៃគូ | ២០១៨ | ២០២០ |
| ប្រជុំពិភាក្សាគណៈកម្មការសហគមន៍រៀបចំផែនការប្រចាំខែ និងឆមាស ខែមករានិងមិថុនា | -គណៈកម្មការទទួលបាននូវបទពិសោធន៍ល្អៗ<br>-មានផែនការសមស្រប ជាក់លាក់ ដើម្បីចុះអនុវត្តន៍ការងារ | ១៦៥<br>(២ដង/ឆ្នាំ) | -គណៈកម្មការ<br>-ក្រុមល្បាត<br>-អាជ្ញាធរមូលដ្ឋាន<br>-អង្គភាពពាក់ព័ន្ធ | ២០១៨ | ២០២១ |
| អនុវត្តន៍ផែនការ៖<br>(រៀបចំកំលាំងចុះ បង្ក្រាបដល់ទីកន្លែងដោយទំនាក់ទំនង និងសហការជាមួយអាជ្ញាធរមូលដ្ឋាន អង្គភាពពាក់ព័ន្ធ និងអង្គការដៃគូ) (៤ដង/ខែ = ១៤៤/ដង) ជាប្រចាំ | -បទល្មើសនេសាទថយចុះ និងឈានទៅលុបបំបាត់ទាំងស្រុង<br>-ធនធានជលផលកើនឡើង<br>-ជីវភាពសមាជិកស.នធូរធារ | ៤.៦៤០ | គណៈកម្មការ សមាជិកស.ន<br>អាជ្ញាធរមូលដ្ឋាន<br>ជំនាញជលផល<br>ស្ថាប័នពាក់ព័ន្ធ | ២០១៨ | ២០២១ |
| មធ្យោបាយនិងសម្ភារ ៖<br>-សាំងនិងប្រេងបាត<br>-អាវភ្លៀង ពិល មួក<br>-កាតទូរស័ព្ទ អាយកូមទាក់ទង<br>-ម៉ាស៊ីនថត | មានលទ្ធភាពចុះល្បាតដោយមានប្រសិទ្ធិភាព | ១.៥៤៦ | គណៈកម្មការ សមាជិកស.ន<br>អាជ្ញាធរមូលដ្ឋាន<br>ជំនាញជលផល<br>អង្គការដៃគូ | ២០១៨ | ២០១៩ |
| ទិញទូកស្នាច់និងម៉ាស៊ីនថ្មីចំនួន ២គ្រឿង | មានមធ្យោបាយចុះល្បាត | ២.០០០ | គណៈកម្មការ<br>ជំនាញជលផល<br>អង្គការដៃគូ | ២០១៨ | ២០២០ |

**គ៦-ផែនការប្រជុំប្រចាំខែនិងទិញសម្ភារអនុវត្តន៍ការងាររបស់គណៈកម្មការសហគមន៍នេសាទ**

ផែនការប្រជុំប្រចាំខែនិងទិញសម្ភារអនុវត្តន៍ការងាររបស់គណៈកម្មការសហគមន៍នេសាទ ត្រូវបានរៀបចំដូចខាងក្រោម៖

| សកម្មភាព | លទ្ធផលរំពឹងទុក | ប៉ាន់ប្រមាណតម្លៃ(ដុល្លា) | អ្នកចូលរួម | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| ប្រជុំគណៈកម្មការសហគមន៍នេសាទនៅសប្តាហ៍ទី២នៃខែ | -របាយការណ៍លទ្ធផលសម្រេចបានក្នុងខែនីមួយៗ<br>-មានផែនការណ៍អនុវត្តន៍បន្ត | ៦៦០ | -គណៈកម្មការ<br>-ក្រុមល្បាត | ២០១៨ | ២០២១ |
| ប្រជុំជាមួយអាជ្ញាធរឃុំ ឬស្ថាប័នពាក់ព័ន្ធ | -ទទួលព័ត៌មាន និងផ្តល់របាយការណ៍លទ្ធផលសម្រេចបានក្នុងខែនីមួយៗ<br>-បញ្ចូលផែនការណ៍ជាមួយផែនការឃុំនិងផែនការស្ថាប័នពាក់ព័ន្ធ | ៥៤០ | -អាជ្ញាធរឃុំ<br>-ស្ថាប័នពាក់ព័ន្ធ<br>-គណៈកម្មការ | ២០១៨ | ២០២១ |
| -សម្ភារការិយាល័យ<br>-ទិញក្រដាស់ ប៊ិច<br>-ព្រីនឯកសារ កូបពី<br>-ការទំនាក់ទំនង | មានសម្ភារការិយាល័យសម្រាប់ប្រើប្រាស់ | ៣០០ | គណៈកម្មការ | រយៈពេល៣ឆ្នាំ | |

**គ៧-ផែនការផ្សព្វផ្សាយនិងបណ្តុះបណ្តាល**

ផែនការផ្សព្វផ្សាយនិងបណ្តុះបណ្តាលត្រូវបានរៀបចំឡើង ដើម្បីពង្រឹងសមត្ថភាពដល់សហគមន៍នេសាទដូចមានខាងក្រោម ៖

| សកម្មភាព | លទ្ធផលរំពឹងទុក | ប៉ាន់ប្រមាណតម្លៃ (ដុល្លា) | អ្នកចូលរួម | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| ផែនការផ្សព្វផ្សាយ | | | | | |
| ប្រជុំផ្សព្វផ្សាយស្តីពី៖<br>-ច្បាប់ជលផល ឯកសារគតិយុត្តិនានាដែលពាក់ព័ន្ធនឹងស.ន<br>-លក្ខន្តិកៈបទបញ្ជាផ្ទៃក្នុង ស.ន ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍<br>-ការប្រើប្រាស់និងការទុកដាក់ថ្នាំកសិកម្មនិង<br>-បទពិសោធន៍ដែលទទួលបាន | -សមាជិកសហគមន៍នេសាទនិងអ្នកខាងក្រៅមានការយល់ដឹងនិងអនុវត្តន៍តាម<br>-សមាជិកនិងប្រជាពលរដ្ឋចូលរួមអនុវត្តន៍តាមផែនការនិងវិធានច្បាប់នានា ដែលបានផ្សព្វផ្សាយ<br>-ផលត្រីនៅក្នុងសហគមន៍មានការកើនឡើងប្រជាពលរដ្ឋអាចរកត្រីបានច្រើននាំឱ្យជីវភាពធូរធារ | ១.៥៤៨ | គណៈកម្មការ,សមាជិកស.ននិងអ្នកក្រៅស.ន អាជ្ញាធរមូលដ្ឋាន ជំនាញជលផល, អង្គការដៃគូ | មេសា-មិថុនា/រៀងរាល់ឆ្នាំ | |

| | | | | | |
|---|---|---|---|---|---|
| -ចែកចាយឯកសារផែនការប្រើប្រាស់ឧបករណ៍ដល់អ្នកនេសាទ១ដង/ឆ្នាំ<br>-ចែកចាយឯកសារនានា | | ៤៥០ | | មិថុនា ២០១៨ | មិថុនា ២០២០ |
| បិទផ្សាយឯកសារ ១ដង/ឆ្នាំ | | ១៦០ | | ២០១៨ | ២០២០ |
| ផ្សព្វផ្សាយជ្រើសរើសក្រុមយុវជនចូលជាសមាជិកសហគមន៍នេសាទឃុំទំនប់ | មានយុវជនចូលរួមក្នុងការងារគ្រប់គ្រងធនធានជលផលក្នុងសហគមន៍នេសាទ | ៦០០ | សមាជិកសហគមន៍នេសាទ | ២០១៨ | ២០១៩ |
| ផែនការបណ្តុះបណ្តាល | | | | | |
| វគ្គបណ្តុះបណ្តាលពីរបៀបរៀបចំលិខិតរដ្ឋបាល ៖<br>-របាយការណ៍<br>-កំណត់ហេតុ<br>-គម្រោងស្នើសុំថវិកា<br>-គម្រោងថវិកានិងការគ្រប់គ្រងថវិកាស.ន | គណៈសហគមន៍នេសាទ សមាជិកស.ន អ្នកពាក់ព័ន្ធបានយល់ដឹងនិងអាចអនុវត្តន៍បានក្នុងការងារជាក់ស្តែង | ១.៤០០ | គណៈកម្មការនិងសមាជិកស.ន អាជ្ញាធរមូលដ្ឋាន អ្នកពាក់ព័ន្ធ | ២០១៨ | ២០១៩ |
| វគ្គបណ្តុះបណ្តាលពីការប្រើប្រាស់កំព្យូទ័រ | គណៈសហគមន៍នេសាទ (២នាក់) | ៣២៥ | គណៈកម្មការ ស.ន | មីនា/២០១៨ | |
| វគ្គបណ្តុះបណ្តាលវិធីសាស្ត្រការប្រមូលព័ត៌មាន | គណៈកម្មការសហគមន៍នេសាទបានយល់ដឹងនិងអាចអនុវត្តន៍បានក្នុងការងារជាក់ស្តែង | ៤០០ | គណៈកម្មការ ស.ន | កញ្ញា/២០១៨ | |
| វគ្គបណ្តុះបណ្តាលយេនឌ័រនិងការវិភាគយេនឌ័រ | គណៈសហគមន៍នេសាទសមាជិកស.នបានយល់ដឹងនិងអាចអនុវត្តន៍បានក្នុងការងារជាក់ស្តែង | ៤០០ | គណៈកម្មការនិងសមាជិកស.ន អាជ្ញាធរមូលដ្ឋាន | មករា/២០១៩ | |
| វគ្គបណ្តុះបណ្តាលស្តីពីការប្រែប្រួលអាកាសធាតុ | គណៈសហគមន៍នេសាទសមាជិកស.នបានយល់ដឹងនិងអាចអនុវត្តន៍បានក្នុងការងារជាក់ស្តែង | ៥០០ | គណៈកម្មការនិងសមាជិកស.ន អាជ្ញាធរមូលដ្ឋាន | មិថុនា/២០១៩ | |
| វគ្គបណ្តុះបណ្តាលពី៖<br>-ការគ្រប់គ្រងនិងសារៈសំខាន់នៃធនធានធម្មជាតិ<br>-សិទ្ធិជាមូលដ្ឋានលើធនធានធម្មជាតិ | គណៈសហគមន៍នេសាទ សមាជិកស.ន ប្រជាពលរដ្ឋ សិស្ស និស្សិតបានយល់ដឹងនិងអាចអនុវត្តន៍បានក្នុងការងារជាក់ស្តែង | ៦៥០ | គណៈកម្មការនិងសមាជិកស.ន អាជ្ញាធរមូលដ្ឋាន សិស្ស,និស្សិត | ២០១៩ | |

គ៨- ផែនការបង្កើតមុខរបរសមាជិកក្នុងសហគមន៍នេសាទ

ផែនការបង្កើតមុខរបរសមាជិកក្នុងសហគមន៍នេសាទ ត្រូវបានរៀបចំឡើងដូចខាងក្រោម៖

| សកម្មភាព | លទ្ធផលរំពឹងទុក | ប៉ាន់ប្រមាណតម្លៃ(ដុល្លា) | អ្នកចូលរួម | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| **ផែនការបណ្តុះបណ្តាល** | | | | | |
| បច្ចេកទេសដាំបន្លែ | -មានចំណេះដឹង<br>-មានមុខរបរ<br>-បង្កើនប្រាក់ចំណូល | ៨០០ | គណៈកម្មការនិងសមាជិកស.ន | ២០១៨ | |
| ចិញ្ចឹម (ត្រី កង្កែប អន្ទង់) ក្នុងស្រះ អាង | | ១.៥០០ | | ២០១៨ | |
| បច្ចេកទេសលើដំណាំស្រូវ និងការប្រើប្រាស់ជីឬថ្នាំកសិកម្ម | | ៨០០ | | ២០១៨ | |
| បច្ចេកទេសកសិកម្មចម្រុះ និងកសិកម្មបន្ត | | ៨០០ | | ២០១៩ | |
| កែច្នៃផលនេសាទ | | ១.៥០០ | | ២០១៩ | |
| **ផែនការបង្កើតក្រុមមុខរបរ** | | | | | |
| ក្រុមដាំបន្លែ | -គណៈកម្មការនិងសមាជិកនេសាទបង្កើតឡើងជាក់ស្តែង<br>-មានបន្លែផ្គត់ផ្គង់ដល់តំបន់ទស្សនាកំសាន្ត និងទីផ្សារ<br>- មានមុខរបរបង្កើនប្រាក់ចំណូល | ៥០០ | គណៈកម្មការនិងសមាជិកស.ន | ២០១៨ | ២០១៩ |
| ក្រុមកសិកម្មចម្រុះ និងកសិកម្មបន្ត | -គណៈកម្មការនិងសមាជិកស.នបង្កើតឡើងជាក់ស្តែង<br>-មានផលិតផលផ្គត់ផ្គង់ដល់តំបន់ទស្សនាកំសាន្ត និងទីផ្សារ<br>- មានមុខរបរបង្កើនប្រាក់ចំណូល | ១.០០០ | គណៈកម្មការនិងសមាជិកស.ន | ២០១៨ | ២០១៩ |
| ក្រុមកែច្នៃផលនេសាទ | គណៈសហគមន៍និងសមាជិកស.នបង្កើតឡើងជាក់ស្តែង<br>-មានផលិតផលផលផលផ្គត់ផ្គង់ដល់តំបន់ទស្សនាកំសាន្តនិងទីផ្សារ<br>-មានមុខរបរបង្កើនប្រាក់ចំណូល | ៥០០ | គណៈកម្មការនិងសមាជិកស.ន | ២០១៨ | ២០១៩ |

គ៩- ផែនការបង្កើតកន្លែងទស្សនាកំសាន្តក្នុងសហគមន៍នេសាទ (អេកូទេសចរណ៍)

ផែនការបង្កើតកន្លែងទស្សនាកំសាន្តក្នុងសហគមន៍នេសាទ ត្រូវបានរៀបចំឡើងនៅតំបន់ត្រពាំងទំនប់ និង ត្រពាំងស្នោ មានដូចខាងក្រោម ៖

| សកម្មភាព | លទ្ធផលរំពឹងទុក | ប៉ាន់ប្រមាណតម្លៃ (ដុល្លា) | អ្នកចូលរួម | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| ប្រជុំផ្សព្វផ្សាយ<br>-លើកដំបូង<br>-ពេលដំណើរការ | គណៈសហគមន៍នេសាទ សមាជិកស.ន បានយល់ដឹង និងអាចអនុវត្តន៍បាន ក្នុងការងារជាក់ស្តែង | ១.១០០ | -គណៈកម្មការ សមាជិកស.ន<br>-អាជ្ញាធរភូមិ ឃុំ និងស្រុក<br>-ជំនាញជលផល<br>-ប៉ូលីស | ២០១៨ | ២០១៨ |
| ទស្សនៈកិច្ចសិក្សា | មានបទពិសោធន៍ស្តីពីការរៀបចំកន្លែងទស្សនាកំសាន្ត | ១.០៣៥ | | ២០១៨ | ២០១៨ |
| រៀបចំទីតាំងទស្សនាកំសាន្ត<br>- ស្លាកសញ្ញាទីតាំងចំនួន១<br>-ដាំដើមឈើចំនួន១០០ដើម<br>-សាងសង់រោងប្រជុំ<br>រោងលម្ហែចំនួន១២<br>-ទូកដឹកជញ្ជូនភ្ញៀវចំនួន៤<br>-ធុងសម្រាមចំនួន១៥<br>-បង្គន់អនាម័យ(បុរស/ស្ត្រី)<br>-បណ្តាញអគ្គិសនី<br>-ផលិតសៀវភៅណែនាំ | ដំណើរការបង្កើតតំបន់ទស្សនាកំសាន្តទទួលបានជោគជ័យ | ១២.៩០០ | គណៈកម្មការ | ២០១៨ | ២០១៩ |
| បង្កើតក្រុម | -ក្រុមបដិសណ្ឋារកិច្ច<br>-ក្រុមសេវាម្ហូបអាហារ<br>-ក្រុមរោងសម្រាកលម្ហែ<br>-ក្រុមផ្ទះស្នាក់នៅ<br>-ក្រុមអាវពោងហែលទឹក<br>-ក្រុមដឹកជញ្ជូន<br>-ក្រុមផ្ញើរយានយន្ត<br>-ក្រុមផ្គត់ផ្គង់ផលិតផលកសិកម្ម<br>-ក្រុមលក់ផលិតផលកែច្នៃ<br>-ក្រុមកសិកម្មបង្ហាញនិងដើម្បីទេសភាព | ១.២០០ | គណៈកម្មការនិង សមាជិកស.ន | ២០១៨ | ២០១៩ |
| ប្រជុំរៀបចំគោលការណ៍ផ្ទៃក្នុងរបស់ក្រុមមុខរបរ | មានលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងរបស់ក្រុមនីមួយៗក្នុងការអនុវត្តន៍ | ៨០០ | គណៈកម្មការ និង សមាជិកស.ន | ២០១៨ | ២០១៩ |
| សន្តិសុខ សណ្តាប់ធ្នាប់និង អនាម័យ | ធានាសន្តិសុខ សណ្តាប់ធ្នាប់ និង អនាម័យក្នុងតំបន់ទស្សនាកំសាន្ត | ១២០ | គណៈកម្មការនិង សមាជិកស.ន | ២០១៨ | ២០១៩ |

## គ១០- ផែនការសាងសង់ស្នាក់ការសហគមន៍នេសាទ

ផែនការសាងសង់ស្នាក់ការសហគមន៍នេសាទ នៅទីតាំងទំនប់ត្រពាំងស្មោ (ចំណុចកែងត្រពាំង) ដោយមានទំហំ (១៥ម៉ែត្រx៣០ម៉ែត្រ) ត្រូវបានរៀបចំដូចខាងក្រោម៖

| សកម្មភាព | លទ្ធផលរំពឹងទុក | ប៉ាន់ប្រមាណតម្លៃ (ដុល្លា) | អ្នកចូលរួម | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| ផ្សព្វផ្សាយឱ្យបានទូលំទូលាយដល់សមាជិកសហគមន៍ និងអ្នកពាក់ព័ន្ធ | -សមាជិកស.ននិងប្រជាពលរដ្ឋមានការឯកភាពនិងចូលរួមអនុវត្តន៍តាមផែនការ<br>-អនុវត្តន៍បានតាមផែនការ | ២០០ | គណៈកម្មការ សមាជិកស.ន ស្ថាប័នពាក់ព័ន្ធ អង្គការដៃគូ | ២០១៨ | ២០១៨ |
| សាងសង់ស្នាក់ការសហគមន៍នេសាទ ទំហំ៦មx៨ម ធ្វើពីបេតុងគ្រឿងដែក ប្រក់ក្បឿង ដោយមានបង្គន់អនាម័យ | - សហគមន៍នេសាទមានកន្លែងសម្រាប់ធ្វើការងារ<br>-មានស្មារតីចូលរួមក្នុងការងារសហគមន៍នេសាទ<br>-មានលទ្ធភាពពេញលេញក្នុងការការពារ គ្រប់គ្រង កន្លែងនេសាទសហគមន៍ | ៦.៥០០ | គណៈកម្មការ សមាជិកស.ន ស្ថាប័នពាក់ព័ន្ធ អង្គការដៃគូ | ២០១៩ | ២០១៩ |
| ទិញតុ ទូ កៅអី ក្តារខៀន កំព្យូទ័រ | មានសម្ភារសម្រាប់ប្រើប្រាស់ | ១.៥០០ | | | |
| បណ្តាញអគ្គីសនី (ប្រព័ន្ធសុលឡា) | មានថាមពលអគ្គីសនីសម្រាប់ស.នធ្វើការងារ | ៥០០ | | ២០១៩ | ២០១៩ |
| រៀបចំប្រព័ន្ធទឹកស្អាត(រៀបចំអាង) | មានទឹកស្អាតសម្រាប់ប្រើប្រាស់ | ២.៥០០ | | ២០១៩ | ២០១៩ |

## គ១១- ផែនការបង្កើតក្រុមឥណទានដើម្បីបង្កើនមុខរបរ

ផែនការបង្កើតក្រុមឥណទាន ដើម្បីបង្កើនមុខរបរ ត្រូវបានរៀបចំដូចខាងក្រោម៖

| សកម្មភាព | លទ្ធផលរំពឹងទុក | ប៉ាន់ប្រមាណតម្លៃ(ដុល្លា) | អ្នកចូលរួម | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| ផ្សព្វផ្សាយ ជ្រើសរើសសមាជិកក្រុមឥណទាន | ក្រុមឥណទានសហគមន៍នេសាទយុំទំនប់ ត្រូវបានបង្កើតឡើងនៃគណៈកម្មការនិងសមាជិកស.ន | ២០០ | គណៈកម្មការនិងសមាជិកស.ន | ២០១៨ | ២០១៩ |
| ប្រជុំរៀបចំគោលការណ៍ផ្ទៃក្នុងក្រុមឥណទាន | -មានលក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុងរបស់ក្រុមឥណទាន<br>-មានដំណើរការល្អ (ខ្ចី សង) | ២០០ | គណៈកម្មការនិងសមាជិកស.ន | ២០១៨ | ២០១៩ |
| ផ្តល់ឥណទាននិងប្រមូលបដិភាគ | មានទុនសម្រាប់ចាប់ផ្តើមមុខរបរ | ១.០០០ | គណៈកម្មការនិងសមាជិកស.ន | ២០១៨ | ២០១៩ |
| ប្រជុំប្រចាំខែ | -របាយការណ៍ឥណទាន<br>-ការរីកចម្រើននូវមុខរបរ | ២៧០ | ក្រុមឥណទាន | ២០១៨ | ២០២១ |

**គ១២-ផែនការអភិវឌ្ឍន៍វារីវប្បកម្មក្នុងសហគមន៍នេសាទ**

ផែនការសម្រាប់អភិវឌ្ឍន៍វារីវប្បកម្មក្នុងសហគមន៍ ត្រូវបានរៀបចំឡើងដូចខាងក្រោម ៖

| ប្រភេទវារីវប្បកម្ម | ចំនួន | ប្រភេទ កូនត្រី ពូជ | បរិមាណ កូនត្រីពូជ | ប៉ាន់ស្មាន តម្លៃ(ដុល្លា) | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្ដើម | ថ្ងៃ ខែ ឆ្នាំ ប្រមូលផល |
|---|---|---|---|---|---|---|
| ចិញ្ចឹមត្រីតាមស្រះ (៦គ្រួសារ) | ៦សx១៥មx២០មx២,៥ម | ប្រា អណ្ដែង ឆ្ពិន កាប | ៣០.០០០ | ១.៤០០ | ២០១៨ | ២០២០ |
| ចិញ្ចឹមកង្កែប អន្ទង់ តាមអាង (៦គ្រួសារ) | ៣អx២មx១,៥មx១,២ម | អន្ទង់ | ៣.០០០ | ៣៧៥ | ២០១៨ | ២០២០ |
| | ៣អx២មx១,៥មx១,២ម | កង្កែប | ៣.០០០ | ៣០០ | ២០១៨ | ២០២០ |

**គ១៤-ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍**

ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍ ត្រូវបានរៀបចំឡើងដូចខាងក្រោម ៖

| ប្រភេទ ប្រាក់ចំណូល | សកម្មភាព | ថ្ងៃខែឆ្នាំ ចាប់ផ្ដើម | ថ្ងៃខែឆ្នាំ ចាប់បញ្ចប់ | ចំណូល ដុល្លា | ផ្សេងៗ |
|---|---|---|---|---|---|
| ភាគទានសមាជិកភាព សហគមន៍នេសាទ | -ផ្សព្វផ្សាយការចូលជាសមាជិក និងបង់ប្រាក់សមាជិកភាព<br>-ប្រមូលភាគទាន ២.០០០រៀល/ម្នាក់ | ២០១៨ | ២០២១ | ៧០ | ២.០០០រៀល/នាក់ (១៤០នាក់) |
| ភាគទានប្រចាំឆ្នាំ | -ផ្សព្វផ្សាយដល់សមាជិកបង់ប្រាក់ភាគទាន ប្រចាំឆ្នាំ<br>-ប្រមូលភាគទានប្រចាំ<br>. អ្នកនេសាទ១០.០០០រៀល<br>.អ្នកមិននេសាទ៣.០០០រៀល | ២០១៨ | ២០២១ | ៦៩៣ | -អ្នកនេសាទជាប្រចាំ ចំនួន៧២នាក់<br>-អ្នកនេសាទម្ដងម្កាល ចំនួន៦៨នាក់ |
| កម្រៃអ្នកនេសាទមិនមែនជាសមាជិកនិងអ្នកមកពីក្រៅ | ប្រមូលប្រាក់កម្រៃពី អ្នកនេសាទមិនមែនជាសមាជិកនិងអ្នកមកពីក្រៅ ៤០.០០០រៀល/ទូក/រដូវ | ២០១៨ | ២០២១ | ២.១០០ | -អ្នកនេសាទមិនមែនជាសមាជិកចំនួន៥៣នាក់<br>-អ្នកមកពីក្រៅចំនួន១៧នាក់ |
| សរសេរគម្រោងស្នើសុំថវិកាពី ៖<br>-រាជរដ្ឋាភិបាល<br>-អង្គការដៃគូពាក់ព័ន្ធ<br>-សប្បុរសជន | -ទំនាក់ទំនងជាមួយមន្ទីរពាក់ព័ន្ធជុំវិញខេត្ត អង្គការដៃគូពាក់ព័ន្ធ និងសប្បុរសជន<br>-សរសេរគម្រោងស្នើសុំថវិកា<br>-តាមដាននិងវាយតម្លៃ | ២០១៨ | ២០២១ | ៩០.៧៣១ | សរសេរគម្រោងស្នើសុំថវិកា ចំណាយ៥០០ដុល្លា |
| សរុប | | | | ៩៣.៥៩៤ | |

ឃ. ផែនការយុទ្ធសាស្រ្ត

ដើម្បីអនុវត្តផែនការឱ្យទទួលបានជោគជ័យ យុទ្ធសាស្រ្តមួយចំនួនត្រូវបានរៀបចំដូចខាងក្រោម ៖

- បង្កើតគណៈកម្មការសម្រាប់អនុវត្តតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តផែនការរួមមានសមាជិកគណៈកម្មការសហគមន៍នេសាទចាស់ទុំ ដែលមានបទពិសោធន៍ និងចំណេះដឹងល្អៗ ជាពិសេសបញ្ហានេសាទ
- ស្នើសុំជំនួយបច្ចេកទេសពីរដ្ឋបាលជលផលមានសមត្ថកិច្ច ដើម្បីជួយផ្តល់យោបល់ចំពោះផែនការណាដែលទាក់ទង និងបច្ចេកទេសជលផល ដូចជា ការធ្វើផែនការកន្លែងអភិរក្សមេពូជត្រី ការរៀបចំកន្លែង អភិរក្សព្រៃ លិចទឹក កន្លែងអភិរក្សជីវៈចម្រុះ ការស្តារឡើងវិញ ការកំណត់ឧបករណ៍នេសាទ ការចិញ្ចឹមត្រី ការរកថវិកាទ្រទ្រង់ជាដើម
- រៀបចំយុទ្ធសាស្រ្តទំនាក់ទំនងជាមួយស្ថាប័នជំនាញ អង្គការដៃគូ គម្រោង និងម្ចាស់ជំនួយ ដើម្បីទទួលបាន ការឧបត្ថម្ភគាំទ្របច្ចេកទេស និងថវិការសម្រាប់ដំណើរការអនុវត្តន៍ផែនការគ្រប់គ្រង
- រៀបចំផែនការអនុវត្តន៍តាមដំណាក់កាលនីមួយៗ ដោយជាក់លាក់និងផែនការសកម្មភាពប្រចាំឆ្នាំ
- ទាក់ទងជាមួយរដ្ឋបាលជលផល និងស្ថាប័នពាក់ព័ន្ធ ដើម្បីសុំការគាំទ្រថវិកា និងជួយរកដៃគូសម្រាប់ទ្រទ្រង់ផែនការគ្រប់គ្រងសហគមន៍នេសាទ
- ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ដល់សមាជិកសហគមន៍នេសាទ អ្នកពាក់ព័ន្ធសំខាន់ៗ ដើម្បីជម្រុញការចូលរួម និងគាំទ្រដល់ការអនុវត្តផែនការគ្រប់គ្រងនេះ
- កៀងគរការចូលរួមចំណែករបស់សមាជិកសហគមន៍នេសាទ
- រៀបចំវិធានការចំពោះអ្នកនេសាទមកពីខាងក្រៅសហគមន៍នេសាទ
- ពង្រឹងសមត្ថភាពបច្ចេកទេស និងគ្រប់គ្រងរបស់គណៈកម្មការសហគមន៍នេសាទ
- ចងក្រងក្រុមអ្នកនេសាទទៅតាមប្រភេទឧបករណ៍នេសាទ ដើម្បីចូលរួមអនុវត្តន៍ផែនការ
- ធ្វើសមាហរណកម្មបញ្ចូលផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ។

## តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ឃុំទំនប់ រយៈពេល ៣ ឆ្នាំ (មីនា ២០១៨ ដល់ កុម្ភៈ ២០២១)

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានចំណាយ | ប្រភពជំនួយ | ពេលផ្តើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| គ១. ផែនការប្រើប្រាស់ឧបករណ៍នេសាទ | ធ្វើនេសាទដោយឧបករណ៍នេសាទគ្រួសារ | -មាននិរន្តរភាពធនធាន<br>-បង្កើនប្រាក់ចំណូល | | សមាជិកនិងគណៈកម្មការ | ២០១៨ | ២០២១ | |
| គ២.ផែនការកែលម្អកន្លែងនេសាទសហគមន៍ | -ស្វែងរកចំណុចទីតាំងជាក់ស្តែងលើផែនដី តាមនិយាមកាលើផែនទី ឬប្រកាស<br>-សាងសង់បង្គោលព្រំស.ន ធ្វើពីស៊ីម៉ង់និងសរសេរអក្សរលើបង្គោល | -ស្គាល់ចំណុចនិយាមកាលើផែនដី ដើម្បីបោះបង្គោល<br>-សមាជិកស.នបានស្គាល់ព្រំប្រទល់កន្លែងនេសាទសហគមន៍បានច្បាស់លាស់<br>-កាត់បន្ថយការរំលោភដីព្រៃ | ៤.៣៨០ | - ស.ន.យ.ទ.ន<br>- រាជរដ្ឋាភិបាល<br>- អង្គការដៃគូ<br>- សប្បុរសជន | ២០១៨ | ២០១៩ | |
| | -ប្រជុំផ្សព្វផ្សាយដល់អ្នកពាក់ព័ន្ធ<br>-សិក្សានិងកំណត់ទីតាំងជាក់ស្តែង<br>-ប្រើគ្រឿងចក្រស្តារឡើងវិញ<br>-អាចម៍ដីរៀបចំជុំវិញត្រពាំង<br>-សាសង់ទំនប់បង្ហៀរ | -ត្រីមានជម្រក<br>-ព្រៃលិចទឹកបានគង់វង្ស<br>-ត្រីកើន<br>-មានទឹកប្រើប្រាស់ | ២៥.៥០០ | | ២០១៨ | ២០២១ | ២ ទីតាំង |
| គ៣.ផែនការកំណត់និងរៀបចំកន្លែងអភិរក្ស | -ផ្សព្វផ្សាយឱ្យបានទូលំទូលាយ<br>-បោះបង្គោលព្រំកន្លែងអភិរក្ស<br>-ដាក់ស្លាកសញ្ញា | -មានត្រីមេពូជ<br>-ត្រីកើនឡើងវិញ<br>-ព្រៃលិចទឹកកើនឡើងវិញ | ៤.៧០០ | - ស.ន.យ.ទ.ន<br>- រាជរដ្ឋាភិបាល<br>- អង្គការដៃគូ | ២០១៨<br>២០១៩ | ២០១៩<br>២០២០ | |
| គ៤.ផែនការគ្រប់គ្រងព្រៃលិចទឹក | -ផ្សព្វផ្សាយ ឱ្យបានទូលំទូលាយ<br>-បោះបង្គោលព្រំព្រៃ/ដាក់ស្លាកសញ្ញា | -ស្គាល់ច្បាស់ព្រំព្រៃលិចទឹក<br>-ព្រៃលិចទឹកបានគង់វង្ស<br>-មានជម្រកត្រីរស់នៅ | ១.៨៨០ | - ស.ន.យ.ទ.ន<br>- រាជរដ្ឋាភិបាល<br>- អង្គការដៃគូ | ២០១៨<br>២០១៩ | ២០១៩<br>២០២០ | |
| គ៥.ផែនការទប់ស្កាត់បទល្មើសជលផល | -ប្រជុំផ្សព្វផ្សាយ<br>-ប្រជុំរៀបចំផែនការល្បាត<br>-អនុវត្តន៍ផែនការចុះបង្ក្រាបជាក់ស្តែង | -បទល្មើសថយចុះ<br>-ធនធានព្រៃលិចទឹក និងត្រីកើនឡើងវិញ<br>-ផលចាប់ត្រីបានច្រើន | ៥.២៥៥ | - ស.ន.យ.ទ.ន<br>- រាជរដ្ឋាភិបាល<br>- អង្គការដៃគូ<br>- សប្បុរសជន | ២០១៨ | ២០២១ | |
| | ទិញមធ្យោបាយនិងសម្ភារប្រើប្រាស់ | មានមធ្យោបាយ សម្ភារល្បាត | ៣.៥៤៦ | | ២០១៨ | ២០២០ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| គ៦.ផែនការប្រជុំប្រចាំខែ និងទិញសម្ភារអនុវត្តន៍ការងារគណៈកម្មការស.ន | -ប្រជុំគណៈកម្មការស.ន<br>-ប្រជុំជាមួយឃុំឬស្ថាប័ន<br>-ទិញសម្ភារការិយាល័យ | -របាយការណ៍លទ្ធផល<br>-មានអន្តរាគមន៍ពីឃុំនិងស្ថាប័ន<br>-មានសម្ភារការិយាល័យសម្រាប់ប្រើប្រាស់ | ១.៥០០ | - ស.ន.យ.ទ.ន<br>- រាជរដ្ឋាភិបាល<br>- អង្គការដៃគូ<br>- សប្បុរសជន | ២០១៨ | ២០២១ | |
| គ៧.ផែនការផ្សព្វផ្សាយ និងបណ្តុះបណ្តាល | ផ្សព្វផ្សាយជ្រើសរើសក្រុមយុវជនចូលជាសមាជិកសហគមន៍នេសាទ | -គណៈកម្មការ សមាជិកសហគមន៍នេសាទ និងប្រជាពលរដ្ឋមានការយល់ដឹង<br>-អាចយកទៅអនុវត្តន៍បានដោយមានការចូលរួម<br>-មានការគ្រប់គ្រងល្អ ធនធានជលផលសម្បូរឡើងវិញ | ២.១៥៨ | - ស.ន.យ.ទ.ន<br>- រាជរដ្ឋាភិបាល<br>- អង្គការដៃគូ<br>- សប្បុរសជន | ២០១៨ | ២០១៩ | |
| | ផ្សព្វផ្សាយ (ប្រជុំ បិទផ្សាយ ចែកឯកសារ)៖ ជលផល, ឯកសារគតិយុត្តិនានាដែលពាក់ព័ន្ធនឹងស.ន, ផែនការគ្រប់គ្រងស.ន, ការប្រើប្រាស់ថ្នាំកសិកម្ម និងបទពិសោធន៍ដែលទទួលបាន | | | | ២០១៨ | ២០២០ | |
| | បណ្តុះបណ្តាលស្តីពី ៖<br>-របាយការណ៍ កំណត់ហេតុ<br>-គម្រោងស្នើសុំនិងការគ្រប់គ្រងថវិកា<br>-ការប្រើប្រាស់កំព្យូទ័រ<br>-ការប្រមូលព័ត៌មាន<br>-យេនឌ័រនិងការវិភាគយេនឌ័រ<br>-ការប្រែប្រួលអាកាសធាតុ<br>-ការគ្រប់គ្រងនិងសារៈសំខាន់នៃធនធានធម្មជាតិ<br>-សិទ្ធិជាមូលដ្ឋានលើធនធានធម្មជាតិ | | ៣.៦៧៥ | - ស.ន.យ.ទ.ន<br>- រាជរដ្ឋាភិបាល<br>- អង្គការដៃគូ<br>- សប្បុរសជន | ២០១៨ | ២០១៩ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| គ៨.ផែនការបង្កើតមុខរបរសមាជិកក្នុងសហគមន៍ | បណ្តុះបណ្តាលស្តីពី៖<br>-បច្ចេកទេសដាំបន្លែ<br>-ចិញ្ចឹម(ត្រី អន្ទង់ និងកង្កែប)<br>-បច្ចេកទេសលើដំណាំស្រូវនិងប្រើថ្នាំកសិកម្ម<br>-បច្ចេកទេសកសិកម្មចម្រុះនិងបន្ត<br>-ការកែច្នៃផលនេសាទ | -មានចំណេះដឹងនិងបច្ចេកទេសលើមុខរបរ<br>-អាចអនុវត្តន៍បានក្នុងការប្រកបមុខរបរ<br>-ទទួលបានប្រាក់ចំណូលបន្ថែម | ៥.៤០០ | - ស.ន.ឃ.ទ.ន<br>- រាជរដ្ឋាភិបាល<br>- អង្គការដៃគូ<br>- សប្បុរសជន | ២០១៨ | ២០១៩ | |
| | បង្កើតក្រុមមុខរបរ៖<br>-ក្រុមដាំបន្លែឬដំណាំចំការ<br>-ក្រុមកសិកម្មចម្រុះនិងបន្ត<br>-ក្រុមកែច្នៃផលនេសាទ | -មានក្រុមមុខរបរកើតឡើង<br>-មានផលិតផលផ្គត់ផ្គង់ទីផ្សារ<br>-លើកស្ទួយកម្រិតជីវភាព | ៣.០០០ | - ស.ន.ឃ.ទ.ន<br>- រាជរដ្ឋាភិបាល<br>- អង្គការដៃគូ<br>- សប្បុរសជន | ២០១៨ | ២០១៩ | |
| គ៩.ផែនការបង្កើតកន្លែងកំសាន្តក្នុងសហគមន៍នេសាទ (អេកូទេសចរណ៍) | -ផ្សព្វផ្សាយឱ្យបានទូលំទូលាយ<br>-ទស្សនៈកិច្ចសិក្សា<br>-រៀបចំទីតាំងទស្សនាកំសាន្ត<br>-បង្កើតក្រុមមុខរបរ<br>-ប្រជុំរៀបចំគោលការណ៍ផ្ទៃក្នុងនៃក្រុម<br>-សន្តិសុខ សណ្តាប់ធ្នាប់ និងអនាម័យ | -ប្រភពចំណូលដល់សហគមន៍នេសាទ<br>-បង្កើតមុខរបរដល់សមាជិកសហគមន៍នេសាទ<br>-មានភ្ញៀវមកកំសាន្ត | ១៧.១៥៥ | - ស.ន.ឃ.ទ.ន<br>- រាជរដ្ឋាភិបាល<br>- អង្គការដៃគូ<br>- សប្បុរសជន | ២០១៨ | ២០១៩ | |
| គ១០.ផែនការសាងសង់ស្នាក់ការសហគមន៍នេសាទឃុំទំនប់ | -សាងសង់ស្នាក់ការសហគមន៍នេសាទ<br>-ទិញសម្ភារសម្រាប់ប្រើប្រាស់<br>-រៀបចំបណ្តាញអគ្គិសនី<br>-រៀបចំប្រព័ន្ធទឹកស្អាត | - សហគមន៍នេសាទមានការិយាល័យសម្រាប់ធ្វើការ<br>-មានសម្ភារប្រើប្រាស់<br>-មានលទ្ធភាពពេញលេញក្នុងការការពារ គ្រប់គ្រងកន្លែងនេសាទសហគមន៍<br>-មានថាមពលអគ្គិសនីសម្រាប់ស.នធ្វើការងារ<br>-សម្រេចបានសកម្មភាពការងារ | ១១.២០០ | - ស.ន.ឃ.ទ.ន<br>- រាជរដ្ឋាភិបាល<br>- អង្គការដៃគូ<br>- សប្បុរសជន | ២០១៨ | ២០១៩ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| គ១១.ផែនការបង្កើតក្រុមឥណទានដើម្បីបង្កើនមុខរបរ | -ផ្សព្វផ្សាយជ្រើសរើសអ្នកស្ម័គ្រចិត្តបង្កើតក្រុមឥណទាន<br>-រៀបចំរចនាសម្ព័ន្ធក្រុមឥណទាន<br>-ប្រជុំរៀបចំលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង<br>-ផ្តល់ទុនតម្កល់និងចូលរួមបដិភាគ | -មានក្រុមឥណទាន<br>-មានលក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុងរបស់ក្រុមឥណទាន<br>-មានដំណើរការល្អ(ខ្ចី សង) មានទុនចាប់ផ្តើមមុខរបរ<br>-របាយការណ៍ឥណទាន<br>-ការរីកចម្រើននូវមុខរបរ | ១.៦៧០ | - ស.ន.យ.ទ.ន<br>- រាជរដ្ឋាភិបាល<br>- អង្គការដៃគូ<br>- សប្បុរសជន | ២០១៨ | ២០១៩ | |
| | ប្រជុំប្រចាំខែ | | | | ២០១៨ | ២០២១ | |
| គ១២.ផែនការអភិវឌ្ឍន៍វារីវប្បកម្មក្នុងសហគមន៍នេសាទ | -ចិញ្ចឹមត្រីតាមស្រះ<br>-ចិញ្ចឹមកង្កែបនិងអន្ទង់តាមអាង<br>-ទិញកូនត្រី កង្កែប និងអន្ទង់ | -បង្កើតមុខរបរដល់សមាជិកសហគមន៍នេសាទ<br>-មានផលិតផលត្រីផ្គត់ផ្គង់ទីផ្សារ<br>-លើកស្ទួយកម្រិតជីវភាព | ២.០៧៥ | - ស.ន.យ.ទ.ន<br>- រាជរដ្ឋាភិបាល<br>- អង្គការដៃគូ<br>- សប្បុរសជន | ២០១៨ | ២០២០ | |
| គ១៣.ផែនការថវិកាទ្រទ្រង់សហគមន៍នេសាទ | -ប្រមូលភាគទានសមាជិកភាព<br>- ភាគទានប្រចាំឆ្នាំ<br>- កម្រៃពីអ្នកខាងក្រៅ | មានថវិកាអនុវត្តន៍សកម្មភាពគ្រប់គ្រងសហគមន៍នេសាទ | ៩៣.៥៩៤ | -សមាជិកស.ន<br>- រាជរដ្ឋាភិបាល<br>- អង្គការដៃគូ<br>- សប្បុរសជន | ២០១៨ | ២០២១ | |
| | សរសេរគម្រោងស្នើសុំពី ៖ ស្ថាប័នពាក់ព័ន្ធ (មន្ទីរជុំវិញខេត្ត) អង្គការដៃគូនានា និងសប្បុរសជន | | | | ២០១៨ | ២០២១ | |

| សកម្មភាព | ២០១៨ | | | | | | | | | ២០១៩ | | | ២០២០ | | | ២០២១ | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | វិច្ឆិកា | ធ្នូ | មករា | .... | ធ្នូ | មករា | .... | ធ្នូ | មករា | កុម្ភៈ |
| គ១. ផែនការប្រើប្រាស់ឧបករណ៍នេសាទ | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → |
| គ២.ផែនការកែលម្អកន្លែងនេសាទសហគមន៍ | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → |
| គ៣.ផែនការកំណត់និងរៀបចំកន្លែងអភិរក្ស | → | → | → | → | → | → | → | → | → | → | → | → | → | → | → | | |
| គ៤.ផែនការគ្រប់គ្រងព្រៃលិចទឹក | → | → | → | → | → | → | → | → | → | → | → | → | → | → | → | | |
| គ៥.ផែនការទប់ស្កាត់បទល្មើសជលផល | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → |
| គ៦.ផែនការប្រជុំប្រចាំខែនិងទិញសម្ភារការិយាល័យ | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → |
| គ៧.ផែនការផ្សព្វផ្សាយនិងបណ្តុះបណ្តាល | → | → | → | → | → | → | → | → | → | → | → | → | → | → | → | | |
| គ៨.ផែនការបង្កើតមុខរបរសមាជិកសហគមន៍នេសាទ | → | → | → | → | → | → | → | → | → | → | → | → | | | | | |
| គ៩.ផែនការបង្កើតកន្លែងទស្សនាកំសាន្តក្នុងស.ន | → | → | → | → | → | → | → | → | → | → | → | → | | | | | |
| គ១០.ផែនការសាងសង់ស្នាក់ការសហគមន៍នេសាទ | → | → | → | → | → | → | → | → | → | → | → | → | | | | | |
| គ១១.ផែនការបង្កើតក្រុមឥណទានដើម្បីបង្កើនមុខរបរ | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → |
| គ១២.ផែនការអភិវឌ្ឍន៍វារីវប្បកម្មក្នុងសហគមន៍នេសាទ | → | → | → | → | → | → | → | → | → | → | → | → | → | → | → | | |
| គ១៣.ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍ | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → |

សូមគោរពជូន

លោកមេឃុំទំនប់

«ដើម្បីជូនពិនិត្យនិងសម្រួល»

ថ្ងៃ...........ខែ...........ឆ្នាំ...... នព្វស័ក ព.ស២៥៦១

........ថ្ងៃទី.....០៤.........ខែ.......... គ.ស២០១៨

ប្រធានគណៈកម្មការសហគមន៍នេសាទ

ឃុំទំនប់

លេខ..............................

បានឃើញនិងគោរពជូន

លោកនាយខណ្ឌរដ្ឋបាលជលផលកំពង់ចាម

«ដើម្បីជូនពិនិត្យនិងសម្រួល»

ថ្ងៃ...........ខែ...........ឆ្នាំ...... នព្វស័ក ព.ស២៥៦១

.......... ថ្ងៃទី.......០៧.........ខែ.........គ.ស២០១៨

នាយផ្នែករដ្ឋបាលជលផលកងមាស

លេខ..............................

បានឃើញនិងគោរពជូន

លោកនាយផ្នែករដ្ឋបាលជលផលកងមាស

«ដើម្បីជូនពិនិត្យនិងសម្រួល»

ថ្ងៃ...........ខែ...........ឆ្នាំ...... នព្វស័ក ព.ស២៥៦១

ទំនប់ ថ្ងៃទី......០៤.........ខែ.........គ.ស២០១៨

មេឃុំទំនប់

ឈិន.ឆ្វយ

លេខ........................
បានឃើញនិងគោរពជូន
លោកប្រធាន
មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកំពង់ចាម
«ដើម្បីជូនពិនិត្យនិងសម្រួល»
ថ្ងៃ.........................ខែ.............ឆ្នាំ......... នព្វស័ក ព.ស២៥៦១
កំពង់ចាម ថ្ងៃទី...................ខែ............គ.ស២០១៨
នាយខណ្ឌរដ្ឋបាលជលផលកំពង់ចាម

អ៊ុក_ណារិន

លេខ.........................
បានឃើញនិងគោរពជូន
ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា
ប្រធានរដ្ឋបាលជលផល
«ដើម្បីជូនពិនិត្យនិងសម្រេចដោយអនុគ្រោះ»
ថ្ងៃ.........................ខែ............ឆ្នាំ........ នព្វស័ក ព.ស២៥៦១
កំពង់ចាម ថ្ងៃទី..................ខែ..........គ.ស២០១៨
ប្រធាន
មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកំពង់ចាម

គឹម_សាវឿន

លេខ.....................ជផ
បានឃើញនិងឯកភាព
ថ្ងៃ.........................ខែ.............ឆ្នាំ.......... នព្វស័ក ព.ស២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី................ ខែ.......... គ.ស២០១៨
**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា**
**ប្រធានរដ្ឋបាលជលផល**

អេង ជាសាន